**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

# សារលិខិតអបអរសាទរ

**សូមផ្ញើជូន**

**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម**

**ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ជាទីគោរព !

នៅក្នុងឱកាសដ៏មហាឧត្តុង្គឧត្តមប្រសើរថ្លៃថ្លា ប្រកបដោយក្តីសោមនស្សរីករាយ ខ្ញុំនិងភរិយាសូមចូលរួមអបអរសាទរចំពោះឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ក្នុងឱកាស **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ត្រាស់បង្គាប់តែងតាំងជាឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើឧបនាយករដ្ឋមន្ត្រី។

ការត្រាស់បង្គាប់តែងតាំងជា ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើឧបនាយករដ្ឋមន្ត្រី ពិតជាមហាកិត្តិយសដ៏ថ្លៃថ្លាឧត្តុង្គឧត្តម និងពិតជាស័ក្តិសមនឹងគុណបំណាច់របស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ដែលតែងតែលះបង់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី និងពេលវេលា ក្នុងការដឹកនាំក្រុមប្រឹក្សាធម្មនុញ្ញ ទទួលបានលទ្ធផលដ៏ត្រចះត្រចង់ ដើម្បីជាប្រយោជន៍ជាតិ មាតុភូមិជាទីស្នេហានៃយើង បម្រើជាតិ និងប្រជាជន រួមចំណែកការពារសន្តិភាព ស្ថិរភាព ទទួលបាននូវកិត្យានុភាពទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ។

ជាថ្មីម្តងទៀត ខ្ញុំនិងភរិយាសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយបីបាច់ថែរក្សាប្រទានពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរគ្រប់ប្រការជូនចំពោះឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ព្រមទាំងក្រុមគ្រួសារ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំនិងភរិយា។

ថ្ងៃសុក្រ ២កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥

**នាយឧត្តមសេនីយ៍ ទៀ សីហា**